**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៤៦៨ **អយក.ហវ**

ថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥

**ជម្រាបជូន**

- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**

**កម្មវត្ថុ ៖** ករណីបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីពេញលេញរបស់អង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាល ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦។

**យោង ៖** ប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តនីតិវិធីរជ្ជទេយ្យបុរេប្រទានតាមប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបានអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា លើមុខងារគ្រប់គ្រងថវិការជ្ជទេយ្យបុរេប្រទានជូនគ្រប់អង្គភាពថវិកា ក្រោមឱវាទក្រសួងឱ្យប្រើប្រាស់ជាផ្លូវការ។ ក្នុងន័យនេះ ដើម្បីពង្រឹងការរៀបចំថវិការជ្ជទេយ្យបុរេប្រទានឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ភាពប្រាកដប្រជា និងទាន់ពេលវេលា ហើយស្របតាមគោលការណ៍ច្បាប់គតិយុត្តថ្មីៗ ក្រសួងស្នើសុំកំណត់ ដូចខាងក្រោម៖

១-រជ្ជទេយ្យបុរេប្រទាន គឺជាចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំ បន្ទាន់ និងមានចំនួនទឹកប្រាក់តិចតួច ដែលពុំអាចរង់ចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីទូទាត់ត្រង់បានជាអាទិ៍ រួមមានចំណាយលើការទិញសម្ភារតិចតួច និងសេវាកម្មតូចតាច ជាដើម។

២-ការបង្កើតតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ ត្រូវបង្កើតឡើង ដោយជ្រើសរើសយកមាតិកាចំណាយតាមគណនី និងអនុគណនីនៃជំពូក៦០ (ការទិញ) ជំពូក៦១ (សេវាកម្ម) និងជំពូក៦៥ (ឧបត្ថម្ភធន) តែប៉ុណ្ណោះ ដោយត្រូវគិតក្នុងកម្រិតមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាតាមជំពូកដែលជ្រើសរើសក្នុងក្របខណ្ឌកញ្ចប់ថវិកាប្រចាំឆ្នាំរបស់អង្គភាពសាមី ដោយដកទំហំថវិកាសម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់ ដែលជាប្រភេទចំណាយតម្រូវឱ្យមានការស្នើសុំធានាចំណាយ និងចំណាយដែលតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ ចំពោះទំហំថវិកាដែលបានជ្រើសរើសពីអនុគណនី ត្រូវកម្រិតមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាសរុបតាមអនុគណនីនីមួយៗ លើកលែងតែមុខសញ្ញាចំណាយមួយចំនួនដែល ត្រូវបានអនុញ្ញាត



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឱ្យលើស៣០ភាគរយទៅតាមតម្រូវការចាំបាច់នៃចំណាយ ប៉ុន្តែត្រូវរក្សាកម្រិតអតិបរមាមិនឱ្យលើសពី៣០ភាគរយនៃឥណទានថវិកាតាមជំពូកដែលបានជ្រើសរើសយកមកបង្កើតរជ្ជទេយ្យបុរេប្រទានឡើយ។

៣-ទំហំឥណទានថវិកាដែលត្រូវបានជ្រើសរើសពីអនុគណនីនីមួយៗ សម្រាប់រៀបចំបង្កើតរជ្ជទេយ្យបុរេប្រទានត្រូវអនុលោមទៅតាមមុខសញ្ញាចំណាយលម្អិត ដែលបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ និងសារាចរណែនាំលេខ ០១៧ សហវ.ស.រ.អថ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ កន្លងមកផងដែរ ។

៤-អង្គភាពថវិកា ត្រូវរៀបចំបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានទាំងពីរប្រភេទគឺតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី អនុគណនី) និងចំណាត់ថ្នាក់កម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព) ព្រមទាំងត្រូវរៀបចំលិខិតស្នើសុំបង្កើតរជ្ជទេយ្យបុរេប្រទាន ឱ្យបានយ៉ាងយូរត្រឹមបំណាច់សប្តាហ៍ទី៣ នៃខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីបានពិគ្រោះយោបល់ជាមុន ជាមួយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា និង/ឬគណនេយ្យករសាធារណៈនៅអគ្គនាយកដ្ឋានរតនាគារជាតិ។

៥-ករណីអង្គភាពថវិកាទើបបង្កើតថ្មីឬអង្គភាពថវិកាដែលមានការផ្លាស់ប្តូររជ្ជទេយ្យករបុរេប្រទាន ឬរជ្ជទេយ្យករបុរេប្រទានរង ត្រូវពន្លឿនប្រកាសអន្តរក្រសួង ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទានឱ្យទាន់ពេលវេលាសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ ខាងមុខ ដើម្បីបញ្ចៀសការរៀបចំបង្កើតតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានយឺតយ៉ាវ។

៦-ករណីអង្គភាពថវិការៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានមិនស្របតាមលក្ខខណ្ឌ និងបញ្ញត្តិផ្សេងនៃប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ និងមានការយឺតយ៉ាវក្រោយសប្តាហ៍ទី៣ ខែវិច្ឆិកា ឆ្នាំ២០២៥ (មុនឆ្នាំអនុវត្តថវិកា) ក្រសួងនឹងមិនអនុញ្ញាតឱ្យរៀបចំតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ការអនុវត្តថវិកាឆ្នាំ២០២៦ទេ។

៧-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួង ក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការរៀបចំបង្កើតរជ្ជទេយ្យបុរេប្រទាននិងការតែងតាំងរជ្ជទេយ្យករបុរេប្រទាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពថវិកាជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
- អគ្គលេខាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នា.ហិរញ្ញវត្ថុ